គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

()

# សិក្ខាសាលាស្តីពី

# ប្រាតិភោគដោយអនុប្បទាន


**ឧទ្ទេសនាមដោយៈ**

លោកស្រីមេធាវី សេក ច័ន្ទណាផា

លោកមេធាវី លឹម សម្បត្តិ

លោកមេធាវី ហូ លីហួរ

## ១. សញ្ញាណទូទៅ

- ប្រាតិភោគ គឺជាមធ្យោបាយមួយដើម្បីផានាកាតព្វកិច្ច ហើយការធានាកាតព្វកិច្ចត្រូវបានធ្វើឡើងតាមទម្រង់ ៣ ប្រភេទគឺ៖
  1. ការធានាកាតព្វកិច្ចតាមការកំណត់របស់ច្បាប់
  2. ការធានាកាតព្វកិច្ចដោយវត្ថុ
  3. ការធានាកាតព្វកិច្ចដោយបុគ្គល

**ប្រាតិភោគដោយអនុប្បទាន**



## ១.១. និយមន័យ

- ប្រាតិភោគដោយអនុប្បទាន គឺសំដៅទៅលើការណ៍ដែលកូនបំណុល ឬតតិយជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណាត់ទៅឲ្យម្ចាស់បំណុល ដើម្បីធានាកាតព្វកិច្ច។ កម្មវត្ថុនៃប្រាតិភោគអាចជាចលនវត្ថុ ឬចលនវត្ថុផ្តុំគ្នាតែមួយ ដែលបានបង្កើតតាមការព្រមព្រៀងរបស់ភាគី។

ចលនវត្ថុ



ចលនវត្ថុផ្តុំគ្នាតែមួយ






## ការបង្កើតប្រាតិភោគដោយអនុប្បទានលើចលនវត្ថុ (CC888-1)

**ឧទាហរណ៍ទី១ ៖** B ជាម្ចាស់ហាងកាហ្វេមួយកន្លែង។ B បានខ្ចីប្រាក់ចំនួន1000ដុល្លាពី A តែ A បានទាមទារឲ្យ B ដាក់ប្រាតិភោគ។ ដូច្នេះ B បានបង្កើតប្រាតិភោគដោយអនុប្បទានជាមួយ A ដោយយកម៉ាស៊ីនឆុងកាហ្វេរបស់គាត់ជាកម្មវត្ថុនៃប្រាតិភោគ។ ដោយ B បានផ្ទេរការកាន់កាប់ឲ្យទៅ A តាមការព្រមព្រៀង ប៉ុន្តែ B នៅតែបន្តកាន់កាប់ម៉ាស៊ីនឆុងកាហ្វេនោះដដែល។



## ការបង្កើតប្រាតិភោគដោយអនុប្បទានលើចលនវត្ថុផ្តុំគ្នាតែមួយ (CC888-2)

**ឧទាហរណ៍ទី២ ៖** X មានបំណងចង់ពង្រីកកសិដ្ឋានចិញ្ចឹមទា Q របស់គាត់ៗបានខ្ចីប្រាក់ពី Y តែ Y តម្រូវឲ្យ X ដាក់ប្រាតិភោគ។ X បានបង្កើតប្រាតិភោគដោយអនុប្បទានលើសត្វទានៅក្នុងកសិដ្ឋានចំនួន១០០០ក្បាលចំពោះ Y ។ ដូច្នេះ សត្វទាទាំងអស់ដែលមាននៅក្នុងកសិដ្ឋាន Q គឺជាកម្មវត្ថុនៃប្រាតិភោគ បើទោះជា X លក់សត្វទាខ្លះចេញ តែចំនួនសត្វទាថ្មីដែល X ទិញចូលគឺជាផ្នែកមួយនៃប្រាតិភោគ។






១.២. មុខងារ

- ប្រាតិភោគដោយអនុប្បទាន គឺជាការធានាសិទ្ធិលើបំណុល ដោយអនុ-ញ្ញាតិឲ្យអ្នកបង្កើតសិទ្ធិប្រាតិភោគ **អាចប្រើប្រាស់ និង បន្តការកាន់កាប់**វត្ថុ ដែលជាកម្មវត្ថុនៃប្រាតិភោគ។

**ឧទាហរណ៍ទី១ (ករណីបញ្ចាំ) ៖** X បានខ្ចីប្រាក់ចំនួន 1000 ដុល្លារ ពី Y ដោយ Y ទាមទារឲ្យ X យកទ្រព្យមកដាក់បញ្ចាំដើម្បីធានាសិទ្ធិលើបំណុល ។ X បានយកម៉ាស៊ីនកិនស្រូវមកដាក់បញ្ចាំជាមួយ Y។ ដើម្បីបង្កើតសិទ្ធិលើការបញ្ចាំ X ត្រូវតែប្រគល់វត្ថុបញ្ចាំ (ម៉ាស៊ីនកិនស្រូវ) ឲ្យទៅ Y កាន់កាប់ (CC818, 819)។



**ឧទាហរណ៍ទី២ (ករណីប្រាតិភោគដោយអនុប្បទាន) ៖** Y ដំណើរការរោងចក្រកិនស្រូវមួយកន្លែង ហើយមានបំណងពង្រីកអាជីវកម្មរបស់គាត់ Y ចង់ខ្ចីប្រាក់ពី X។ តែ X បានទាមទារឲ្យ Y ផ្តល់ប្រាតិភោគ។ Y មានម៉ាស៊ីនកិនស្រូវដែលមានតម្លៃ ប៉ុន្តែ Y មិនអាចយកម៉ាស៊ីននោះមកដាក់បញ្ចាំទេ ព្រោះគាត់ត្រូវការប្រើម៉ាស៊ីនកិនស្រូវនោះសម្រាប់អាជីវកម្មរបស់គាត់ ។ ក្នុងករណីនេះ Y អាចបង្កើតប្រាតិភោគដោយអនុប្បទានលើម៉ាស៊ីនសម្រាប់ X ហើយ Y នៅតែបន្តកាន់កាប់ប្រើប្រាស់ម៉ាស៊ីន និងអាចពង្រីកអាជីវកម្ម។ ប្រសិនបើ Y ខកខានមិនបានសងប្រាក់ X នោះ X អាចលក់ម៉ាស៊ីន និងទទួលយកប្រាក់វិញបាន។



**ឧទាហរណ៍ទី៣ (ករណីប្រាតិភោគដោយអនុប្បទាន) ៖** Y បើកហាងលក់គ្រឿងប្រាក់មួយកន្លែង ដើម្បីពង្រីកអាជីវកម្ម Y មានបំណងចង់ខ្ចីប្រាក់ពី X។ X បានទាមទារឲ្យ Y ផ្តល់ប្រាតិភោគ។ Y មានគ្រឿងប្រាក់ជាច្រើននៅក្នុងហាងរបស់គាត់ ប៉ុន្តែ Y មិនអាចប្រគល់គ្រឿងប្រាក់នោះសម្រាប់ការបញ្ចាំនោះទេ ព្រោះ Y ត្រូវការរក្សាគ្រឿងប្រាក់ទាំងអស់នៅក្នុងហាងរបស់គាត់សម្រាប់លក់។ ក្នុងករណីនេះ Y អាចបង្កើត ប្រាតិភោគដោយអនុប្បទានលើគ្រឿងប្រាក់ដែលមាននៅក្នុងហាងរបស់ Y ដោយ Y អាចបន្តការកាន់កាប់ និងលក់គ្រឿងប្រាក់នោះ។ នៅពេលដែល Y ដាក់បំពេញឡើង វិញនូវគ្រឿងប្រាក់ថ្មីនៅក្នុងហាងរបស់គាត់ គ្រឿងប្រាក់ថ្មីនោះនឹងក្លាយជាផ្នែកមួយដោយស្វ័យប្រវត្តិនៃវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន។ ប្រសិនបើ Y ខកខានមិនបានសងប្រាក់ដែលបានខ្ចីទៅឲ្យ X នោះ X អាចលក់គ្រឿងប្រាក់ទាំងអស់ និងប្រមូលប្រាក់មកវិញបាន។



## ២. ការបង្កើត និង អានុភាពតតាំង

### ២.១. ការបង្កើត

- ប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើងតាមការព្រមព្រៀងរបស់ភាគី (CC889)។ ជាទូទៅប្រាតិភោគដោយអនុប្បទាន អាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់បាន។

ការព្រមព្រៀងបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន





## ២.២. អានុភាពតតាំង (CC890)

- ដើម្បីតតាំងនឹងតតិយជន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវទទួលបានការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុប្រាតិភោគដោយអនុប្បទាននោះជាចាំបាច់។
- តើម្ចាស់សិទ្ធិប្រាតិភោគ ទទួលបានការកាន់កាប់លើវត្ថុជាកម្មវត្ថុប្រាតិភោគតាមវិធីណា?
- ជាទូទៅការផ្ទេរការកាន់កាប់អាចធ្វើឡើងតាមវិធី ៤ យ៉ាង (CC229)៖
  - ការប្រគល់ដោយជាក់ស្តែង
  - ការប្តូរលក្ខណៈនៃការកាន់កាប់
  - ការប្រគល់ដោយសង្ខេប
  - ការផ្ទេរការកាន់កាប់ដោយបញ្ជា

- **ការប្រគល់ដោយជាក់ស្តែង** គឺជាការផ្ទេរតាមរយៈការប្រគល់វត្ថុកាន់កាប់ (CC229-1)។

**ឧទាហរណ៍ទី១៖** X បានទិញសៀវភៅមួយក្បាលពី Y ហើយបានប្រគល់សៀវភៅនោះឲ្យទៅ X ដោយផ្អែកលើការលក់-ទិញ ។ ដូច្នេះ X បានកាន់កាប់ដោយចំពោះលើសៀវភៅនោះ។ នេះជាការផ្ទេរការកាន់កាប់លើចលនវត្ថុ ប្រសិនបើអចលនវត្ថុអាច ជាការចាកចេញពីអចលនវត្ថុនោះ ហើយប្រគល់ដោយផ្ទាល់ទៅអនុប្បទានិក និងការ ប្រគល់ជាក់ស្តែងនូវប័ណ្ណកម្មសិទ្ធិ និងសោផ្ទះជាដើម។



- **ការប្តូរលក្ខណៈនៃការកាន់កាប់** គឺជាការផ្ទេរការកាន់កាប់ដោយការព្រមព្រៀងរបស់ភាគី ដោយគ្មានការប្រគល់វត្ថុជាក់ស្តែង។ ករណីនេះ អនុប្បទានិកនៃការកាន់កាប់ធ្វើលទ្ធកម្មដោយប្រយោលតាមរយៈអនុប្បទាយី (CC229-2)។

**ឧទាហរណ៍ទី២៖** X បានលក់រថយន្តឲ្យ Y បន្ទាប់មកទៀត X បានជួលរថយន្តនោះពី Y វិញ ។ ដោយនៅតែបន្តការកាន់កាប់ និងប្រើប្រាស់ទៀត បើយើងមើលពីខាងក្រៅឃើញថាការកាន់កាប់នោះមិនបានផ្ទេរទេ ប៉ុន្តែជាក់ស្តែងការកាន់កាប់បានផ្ទេរទៅ Y តាមការព្រមព្រៀងរបស់ភាគីរួចហើយដោយផ្អែកលើកិច្ចសន្យាលក់-ទិញ និងកិច្ចសន្យាជួល។ ក្នុងករណីនេះ X ជាអ្នកកាន់កាប់ដោយផ្ទាល់ហើយ Y ជាអ្នកកាន់កាប់ដោយប្រយោល។



- **ការប្រគល់ដោយសង្ខេប** គឺសំដៅដល់ការផ្ទេរការកាន់កាប់តាមរយៈការព្រមព្រៀងរបស់ភាគី ក្នុងករណីអនុប្បទានិកបានក្តាប់ទុកវត្ថុជាក់ស្តែងនៅក្នុងដៃ ហើយអនុប្បទាយីបានបាត់បង់ការកាន់កាប់ដោយប្រយោលរបស់ខ្លួនផ្ទាប់មាន។

**ឧទាហរណ៍ទី៣៖** X បានជួលរថយន្តពី Y ហើយក្រោយមក X បានទិញរថយន្តដែលគាត់ជួលនោះពី Y តែម្តង។ ក្នុងករណីនេះ Y បានបាត់បង់ការកាន់កាប់ដោយ ប្រយោលតាមរយៈ X ព្រោះថា Y មិនបានកាន់កាប់វត្ថុដោយចំពោះតាំងពីដើមមកហើយលុះដល់ពេលការលក់–ទិញកើតឡើងគាត់មិនមានវត្ថុដែលត្រូវប្រគល់ឲ្យ X ទេ នេះគឺជាការប្រគល់ដោយសង្ខេប។



- **ការផ្ទេរការកាន់កាប់ដោយបញ្ញា** សំដៅទៅលើអ្នកកាន់កាប់ដោយប្រយោលបានបង្កើតនូវកិច្ចព្រមព្រៀងថា ផ្ទេរការកាន់កាប់ទៅឲ្យតតិយជន និងមានករណីកិច្ចត្រូវជូនដំណឹងអំពីហេតុនោះទៅឲ្យអ្នកកាន់កាប់ដោយចំពោះលើវត្ថុនោះបានដឹង។

**ឧទាហរណ៍ទី៤៖** X ជូលផ្ទះឲ្យ Y ហើយស្ថិតក្នុងកំឡុងពេលជូលនោះ X បានលក់ផ្ទះនោះឲ្យទៅ Z។ ដោយ X និង Z មានការព្រមព្រៀងគ្នាដើម្បីផ្ទេរកម្មសិទ្ធិ ដូច្នេះ X មានករណីយកិច្ចត្រូវជូនដំណឹងឲ្យ Y បានដឹងថា Y កាន់កាប់ដោយចំពោះលើទ្រព្យរបស់អ្នកណា។



## ៣. អានុភាព

### ៣.១. អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិប្រាតិភោគដោយអនុប្បទានមានអានុភាពលើ៖

- ❖ វត្ថុភ្ជាប់: វត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុ និងជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។ (CC៨៩១-១)
  - ◦ ជាទូទៅ “វត្ថុភ្ជាប់” រួមបញ្ចូលទាំង “សមាសភាគនៃវត្ថុ” និង “វត្ថុចំណុះ”។



◦ សមាសភាគនៃវត្ថុ: ចំពោះសមាសភាគនៃវត្ថុអ្វីមួយដែលមិនអាចបែងចែកបានដោយមិនបំបែកវត្ថុនោះ ឬដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃវត្ថុនោះទេ។ (CC១២១)






- វត្ថុចំណុះ: វត្ថុដែលភ្ជាប់ទៅនឹងវត្ថុចម្បងក្នុងគោលបំណងដើម្បីបង្កើនតម្លៃវត្ថុចម្បងនោះ។ (CC១២៦)










## ៣.២. ផលដែលអាចកើតមានឡើងពីវត្ថុនៃប្រាតិភោគដោយអនុប្បទាន (CC892)

- Y ឬតតិយជនទទួលការបញ្ឆោពី Y ជាអ្នកកាន់កាប់ (CC892-1)

បង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

X ⟷ Y



លក់

Z



**តើថ្លៃឈ្នួលរថយន្តនេះត្រូវបានទៅលើអ្នកណា?**

- X ឬតតិយជនទទួលការបញ្ជាពី X ជាអ្នកកាន់កាប់ (CC892-2)




**តើថ្លៃឈ្នួលរថយន្តនេះត្រូវបានទៅលើអ្នកណា?**

**ករណីទី 1:** Y ធ្វើអាជីវកម្មរោងចក្រមួយ។ វត្ថុនៃប្រាតិភោគដោយអនុប្បទានគឺម៉ាស៊ីនមួយក្នុងរោងចក្ររបស់ Y។ Y បានរក្សាការកាន់កាប់ម៉ាស៊ីនដោយផ្ទាល់ ប៉ុន្តែ Y បានលក់ម៉ាស៊ីននោះទៅឲ្យ Z ដោយគ្មានការយល់ព្រមពី X។

**តើ X អាចប្រើសិទ្ធិប្រាតិភោគដោយអនុប្បទានរបស់គាត់ចំពោះម៉ាស៊ីនបានដែរឬទេ ដែលបច្ចុប្បន្ននេះត្រូវបានគ្រប់គ្រង និងកាន់កាប់ដោយ Z?**



**ករណីទី 2:** Yធ្វើអាជីវកម្មបើកហាងលក់រូបភាពមួយ។ វត្ថុនៃប្រាតិភោគដោយអនុប្បទានគឺរូបភាពទាំងអស់នៅក្នុងហាងរបស់ Y ហើយ Y បានរក្សាការកាន់កាប់រូបភាពដោយផ្ទាល់។ Y បានបន្តដំណើរការអាជីវកម្មរបស់ខ្លួនលក់រូបភាពទាំងនោះនិងបានលក់រូបភាពមួយទៅឲ្យ Z (រូបភាពQ)។ **(CC893-2, CC894-2)**

**តើ X អាចប្រើប្រាស់សិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ខ្លួនចំពោះរូបភាព Q បានដែរឬទេ ដែលឥឡូវនេះត្រូវបានគ្រប់គ្រង និងកាន់កាប់ដោយ Z?**



**ករណីទី 3:** Y បានបើកដំណើរការរោងចក្រមួយកន្លែង ប៉ុន្តែបានផ្អាករោងចក្រមួយ   រយៈក្នុងគោលបំណងដើម្បីរៀបចំសម្រាប់អាជីវកម្មថ្មី។ Y ខ្ចីប្រាក់ពី X ដើម្បីវិនិយោគក្នុងអាជីវកម្មថ្មី និងប្រគល់ម៉ាស៊ីនចាស់មួយគ្រឿងទៅឲ្យ X សម្រាប់ជាប្រាតិភោគ។ Y បានផ្ទេរការកាន់កាប់ដោយផ្ទាល់លើម៉ាស៊ីនទៅឲ្យ X។ X ត្រូវបានគេសន្មត់ថាបានរក្សាម៉ាស៊ីនជាមួយគាត់ ប៉ុន្តែគាត់បានលក់ម៉ាស៊ីនទៅ Z។

**តើ Z អាចទទួលបានកម្មសិទ្ធិនៃម៉ាស៊ីននេះដែរឬទេ?**



## ៣.៤. ការខូចខាតឬការបាត់បង់វត្ថុនៃប្រាតិភោគដោយអនុប្បទាន

**ករណីទី 1:** នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ Y បានខ្ចីប្រាក់ចំនួន ១ពាន់ដុល្លារ ពី X ដោយបង្កើតកិច្ចព្រមព្រៀងប្រាតិភោគដោយអនុប្បទានលើម៉ាស៊ីនមួយគ្រឿង និងកំណត់សងប្រាក់រយៈពេល ០១ឆ្នាំ។ ប៉ុន្តែនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៦ ម៉ាស៊ីននោះបានខូចប្រើប្រាស់លែងកើត ។

**តើ X ត្រូវធ្វើដូចម្តេច បើបច្ចុប្បន្ននេះម៉ាស៊ីនខូចទៅហើយ?**



**ករណីទី 2:** នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ Y បានខ្ចីប្រាក់ចំនួន ១ពាន់ដុល្លារ ពី X ដោយបង្កើតកិច្ចព្រមព្រៀងប្រាតិភោគដោយអនុប្បទានលើម៉ាស៊ីនមួយគ្រឿង និងកំណត់សងប្រាក់រយៈពេល ០១ឆ្នាំ។ ក្រោយពីខ្ចីប្រាក់រួច X បានដឹងថា Y បានកំពុងព្យាយាមផ្ទេរម៉ាស៊ីនទៅឱ្យតតិយជន។

**តើវិធានការណ៍អ្វីដែល X អាចអនុវត្តក្នុងគោលបំណងដើម្បីបញ្ឈប់ Y ផ្ទេរម៉ាស៊ីនទៅ ឲ្យតតិយជន?**



**ករណីទី 3:** នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ Y បានខ្ចីប្រាក់ចំនួន ១ពាន់ដុល្លារ ពី X ដោយបង្កើតកិច្ចព្រមព្រៀងប្រាតិភោគដោយអនុប្បទានលើម៉ាស៊ីនមួយគ្រឿង និងកំណត់សងប្រាក់រយៈពេល ០១ឆ្នាំ។ ស្រាប់តែនៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ Xបានទៅយកម៉ាស៊ីននោះចេញដោយគ្មានការយល់ព្រមពី Y ឡើយ។

**តើ Y អាចទាមទារយកម៉ាស៊ីននោះមកវិញបានដែរឬទេ បើបច្ចុប្បន្ន X កំពុងតែកាន់កាប់ និងគ្រប់គ្រងលើម៉ាស៊ីននេះ?**



**ករណីទី 1:** Y បានខ្ចីប្រាក់ចំនួន ១ពាន់ដុល្លារ ពី X ដោយបង្កើតកិច្ចព្រមព្រៀងប្រាតិភោគដោយអនុប្បទានលើម៉ាស៊ីនមួយគ្រឿង។ Y បានរក្សាការកាន់កាប់ម៉ាស៊ីនដោយផ្ទាល់ ប៉ុន្តែ Z ដែលជាម្ចាស់បំណុលផ្សេងទៀតរបស់ Y បានធ្វើការអនុវត្តដោយបង្ខំរឹបអូសយកម៉ាស៊ីននោះទៅលក់ដើម្បីសងបំណុល។

**តើ X ត្រូវធ្វើដូចម្តេច បើពេលនេះ Z កំពុងរឹបអូសយកម៉ាស៊ីននេះ? (CCP 365)**



**ករណីទី 2:** Y ខ្ចីប្រាក់ចំនួន ១ពាន់ដុល្លារ ពី X ដើម្បីវិនិយោគក្នុងអាជីវកម្មមួយ និងបានប្រគល់ម៉ាស៊ីនមួយគ្រឿងទៅឲ្យ X សម្រាប់ជាប្រាតិភោគ។ Y បានផ្ទេរការកាន់កាប់ដោយផ្ទាល់លើម៉ាស៊ីនទៅឲ្យ X។ ប៉ុន្តែ Z ដែលជាម្ចាស់បំណុលរបស់ X បានមកធ្វើការអនុវត្តដោយបង្ខំរឹបអូសយកម៉ាស៊ីននោះ។

**តើ Y ត្រូវធ្វើដូចម្តេច បើពេលនេះ Z កំពុងរឹបអូសយកម៉ាស៊ីននេះ? (CCP 365)**



# ៤. ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

## ៤.១. លំហូរ




4: ប្រសិនបើតម្លៃនៃវត្ថុមិនលើសពីទំហំសិទ្ធិលើបំណុល ក៏ត្រូវផ្តល់ដំណឹងដែរ

ប្រាក់ជម្រះ = តម្លៃត្រឹមត្រូវនៃវត្ថុ - ទឹកប្រាក់នៃសិទ្ធិលើបំណុលប្រាតិភោគ

**ករណីទី 1:** Y បានខ្ចីប្រាក់ពី X ដើម្បីវិនិយោគក្រុមហ៊ុនថ្មីមួយ ហើយបានបង្កើតកិច្ចព្រមព្រៀងប្រាតិភោគដោយអនុប្បទានលើម៉ាស៊ីនមួយគ្រឿង។ Y បានរក្សាការកាន់កាប់ម៉ាស៊ីនដោយផ្ទាល់ ។ ដោយសារតែ Y មិនបានបំពេញកាតព្វកិច្ចតាមការសន្យា X បានទាមទារឲ្យ Y ប្រគល់ម៉ាស៊ីន ប៉ុន្តែ Y បានបដិសេធមិនប្រគល់។

**តើ X ត្រូវធ្វើដូចម្តេច?**



**ករណីទី 2:** ដោយសារ Y មិនមានប្រាក់ដើម្បីសងបំណុលរបស់ X។ X បានប៉ាន់ប្រមាណថាតម្លៃនៃម៉ាស៊ីនដែលជាប្រាតិភោគច្រើនជាងបំណុល។ ដូច្នេះ X បានបង់ប្រាក់ជម្រះ ប៉ុន្តែ Y គិតថាចំនួននោះគឺមិនគ្រប់គ្រាន់ទេ។

**តើ Y ត្រូវធ្វើដូចម្តេច?**



**ករណីទី 3:** Y បានប្រគល់ម៉ាស៊ីនមួយគ្រឿងទៅឲ្យ X ដើម្បីទូទាត់បំណុលប្រាតិភោគ។ ក្រោយពីប្រគល់រួច Y បានឈ្នះឆ្នោតជាតិ ហើយមានប្រាក់គ្រប់គ្រាន់សំរាប់ទូទាត់បំណុល។ ដូច្នេះ Y មានបំណងចង់បានម៉ាស៊ីននោះត្រឡប់មកវិញ។

**តើ Y ត្រូវធ្វើដូចម្តេច?**



# អរគុណ!

# សំនួរ និងចម្លើយ